THE SCHOOL DISTRICT OF PHILADELPHIA

ការិយាល័យ អគ្គនាយក

440 North Broad Street
Philadelphia, PA 1913

**William R. Hite, Jr., Ed.D.**
អគ្គនាយក

ថ្ងៃទី ១៩ ខែសីហា ឆ្នាំ ២០២០

ជូនចំពោះសហគមន៍របស់ក្រសួងអប់រំនៃទីក្រុងហ្វីឡាដែលហ្វ្យា៖

ពិបាកនឹងជឿណាស់ថា យើងនៅសល់ពេលតែប៉ុន្មានសប្តាហ៍ទៀតតែប៉ុណ្ណោះ មុននឹងចាប់ផ្តើមនៃឆ្នាំសិក្សា ២០២០-២០២១ ដែលមិនធ្លាប់មានពីមុនមក។ ខណៈពេលដែលឆ្នាំសិក្សានេះ មើលទៅ និង មានអារម្មណ៍ ថាខុសគ្នាខ្លាំង នៅពេលដែលយើងបោះជំហាន ដើម្បីជួយដល់សុខុមាលភាពរបស់មនុស្សគ្រប់រូបក្នុងកំឡុងពេលនៃជម្ងឺរាតត្បាតនៃមេរោគ ខូវីដ-១៩ រឿងមួយដែលនៅតែដដែល គឺការរំភើបចិត្តក្នុងការស្វាគមន៍សិស្សានុសិស្សរបស់យើង សម្រាប់ឆ្នាំសិក្សានៃ ការសិក្សា និង ការរីកចម្រើន នៃឆ្នាំមួយទៀត។

អស់រយៈពេលជាច្រើនខែកន្លងមកនេះ យើងបានខិតខំរៀបចំសម្រាប់ឆ្នាំសិក្សាថ្មីដែលនឹងចាប់ផ្តើមនៅ ថ្ងៃពុធ ទី ២ ខែកញ្ញា ជាមួយការសិក្សាតាមកុំព្យូទ័រ សម្រាប់ សិស្សថ្នាក់មុនមត្តេយ្យ ដល់ថ្នាក់ទី ១២ សម្រាប់ត្រីមាសទី ១។ យើងបាន៖

- ប្រើការយល់ដឹង និងមតិយោបល់ពីនិទាឃរដូវកន្លងទៅនេះ ដើម្បីពង្រឹងវិធីដែលគ្រូនឹងបង្រៀន ហើយក្មេងនឹងរៀន តាមអ៊ីនធឺរណិត
- ឱ្យ នាយកសាលា និង បុគ្គលិកនៅតាមសាលា ចូលរួមការហ្វឹកហ្វឺនវិជ្ជាជីវៈ ដើម្បីជួយដល់តម្រូវការរបស់ សិស្សានុសិស្ស និង ក្រុមគ្រួសារ របស់យើង ដែលគ្រូនឹងចូលរួមនៅពេលពួកគាត់ត្រឡប់មកបង្រៀនវិញ នៅថ្ងៃទី ២៤ ខែសីហា។
- បង្កើតជំនួយសតិអារម្មណ៍ផ្នែកសង្គម ដល់ សិស្សានុសិស្ស និង បុគ្គលិក ដោយទទួលស្គាល់ថាយើងត្រូវតែដោះស្រាយតម្រូវការទាំងនេះជាមុនសិន ដែលជាលទ្ធផលនៃរបួសផ្លូវចិត្តដែលយើងបានជួបប្រទះ ដោយសារ រោគរីករាលដាល និង ការបន្តកើតឡើងជាប្រព័ន្ធនៃភាពអយុត្តិធម៌នៃការប្រកាន់ពូជសាសន៍។
- ការបង្កើតសម្ព័ន្ធភាពសមភាព ដើម្បីជួយ គាស់រំលើង និង លុបបំបាត់ ច្បាប់ និង ការអនុវត្តន៍ ដែលមិនស្មើភាពគ្នា ឬ ប្រកាន់ជាតិសាសន៍ នៅតាមសាលារៀន និង កន្លែងធ្វើការ របស់យើង ហើយបើមិនដូច្នេះទេ បង្កើតក្រសួងអប់រំដែលមានសមភាពជាងនេះ។
- រៀបចំពង្រីកការចែកចាយម្ហូបអាហាររបស់យើង ដើម្បីឱ្យសិស្សានុសិស្សបន្តទទួលបានម្ហូបអាហារមានជីវជាតិ ក្នុងខណៈពេលកំពុងសិក្សាពីផ្ទះ។
- និងអ្វីៗជាច្រើនទៀត។

**យើងក៏បានប្រមូលនូវ គន្លឹះ និង ការក្រើនរំឭក មួយចំនួន នៅក្នុង**<u>បញ្ជីផ្ទៀងផ្ទាត់នៃការវិលត្រឡប់មកសាលារៀនវិញ សម្រាប់ក្រុមគ្រួសារ</u> **ដើម្បីជួយលោកអ្នក និង កូនរបស់លោកអ្នក រៀបចំ និង ត្រៀម សម្រាប់ឆ្នាំសិក្សាថ្មីប្រកបដោយជោគជ័យ។** បើសិនជាលោកអ្នកមិនទាន់ចាប់ផ្តើមទទួលព័ត៍មានអំពីការវិលត្រឡប់មកសាលារៀនវិញ ពីសាលារបស់កូនលោកអ្នកទេ លោកអ្នកនឹងទទួលព័ត៍មានក្នុងពេលឆាប់ៗនេះ។ គោលដៅរបស់យើងគឺធ្វើយ៉ាងណាឱ្យលោកអ្នកមានព័ត៍មានដែលលោកអ្នកត្រូវការទាំងអស់ ដើម្បីចាប់ផ្តើមឆ្នាំសិក្សាឱ្យបានល្អ។

សូមអរគុណចំពោះ ភាពដែលអាចបត់បែនបាន និង ភាពជាដៃគូ របស់លោកអ្នក នៅពេលយើងធ្វើការរួមគ្នាដើម្បីគាំទ្រដល់ឆ្នាំសិក្សា ២០២០-២០២១ ប្រកបដោយ សុវត្ថិភាព និង ជោគជ័យ សម្រាប់យើងទាំងអស់គ្នា។ យើងរង់ចាំជួបលោកអ្នកក្នុងពេលឆាប់ៗនេះ!

ដោយសេចក្តីគោរពរាប់អាន

William R. Hite Jr., Ed.D.
អគ្គនាយក
ក្រសួងអប់រំនៃទីក្រុងហ្វីឡាដែលហ្វ្យា